# ការសម្ភាសន៍របស់អ៊ុំស្រី សែម អង

កៈ អ្នកសំភាសន៍ឈ្មោះ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍សែម អង

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ សែម អង</u>

សង្ខេបៈ អ៊ុំស្រី សែម អង គាត់មានអាយុចិតសិបបួនឆ្នាំ
ហើយគាត់បានកើតនៅភូមិផ្នត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ
ហើយគាត់មានបងប្អូនប្រាំមួយនាក់ ហើយគាត់ជាកូនទី ប្រាំមួយ។
សំរាប់ម្តាយរបស់គាត់បានស្លាប់នៅពេលមកពីជំនាន់ពលពតវិញដោយសារជម្ងឺ
ហើយឪពុករបស់គាត់ទើបស្លាប់បានបីឆ្នាំ ហើយគាត់បានស្លាប់ដោយសារជម្ងឺជរា។
ហើយសំរាប់អ៊ុំស្រីគាត់មានកូនចំនួនប្រាំពីរនាក់។ គាត់មានកូនប្រុសម្នាក់
ហើយកូនស្រីចំនួនប្រាំមួយនាក់។
ហើយនៅសម័យពលពតគេបានអោយគាត់ទៅដល់ស្រុកសណ្តាន់ខេត្តកំពង់ធំ
ហើយគេបានអោយគាត់ទៅច្រូតស្រូវ ហើយដើររកអុសអោយគេ។
គាត់ជាមនុស្សមានសំណាងល្អ
ព្រោះពួកពលពតបានរៀបជប់លៀងអោយដើម្បីយកគាត់ទៅវាយចោលនៅពេលល្ងាច
តែសំណាងល្អដោយគេរំដោះបានចឹងទើបគាត់នៅមានជីវិត។
នៅក្នុងជីវិតរបស់គាត់មានការលំបាកច្រើន ជាពិសេសខាងជីវភាព
គ្រួសារគាត់រកបានព្រឹកខ្វះល្ងាច ហើយរកបានល្ងាចខ្វះព្រឹក
តែគាត់នៅតែមានការតស៊ូជាខ្លាំង។ធ្វើឡើងនៅភូមិផ្នត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ
ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី០៥ ខែ០៦ ឆ្នាំ២០១៨។

កៈ អញ្ចឹងដំបូងជំរាបសួរអ៊ុំស្រី ខ្ញុំឈ្មោះគង់
ចាន់ណាក់ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ ប្រជាជនកម្ពុជា
ដែលធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិច ដែលមានឈ្មោះថា
សាកលវិទ្យាល័យ ប៊ី វ៉ាយ យ៉ូ
ដោយសារតែសាកលវិទ្យាល័យមានគម្រោងដើម្បីថែរក្សាប្រវត្តិរបស់
ប្រជាជនខ្មែរដើម្បីអោយកូនចៅជំនាន់ក្រោយរបស់យើងគាត់អាចរៀនពីប្រវត្តិរបស់ជីដូនជី
តារបស់ពួកគេ។ ហើយសំរាប់ការសម្ភាសន៍មួយនេះយើងធ្វើឡើងនៅភូមិផ្នត់ដំរីខាងត្បូង
ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយយើងធ្វើនៅថ្ងៃទី០៥ ខែ០៦ ឆ្នាំ២០១៨។
ហើយអញ្ចឹងជាដំបូង ខ្ញុំសូមសួរអ៊ុំស្រី តើអ៊ុំស្រីមានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខ៖ ខ្ញុំឈ្មោះ សែម អង។

ក៖ សែម អង! ហើយអញ្ចឹង តើអ៊ុំស្រីមានឈ្មោះហៅក្រៅទេ អ៊ុំស្រី?

ខ៖ អត់មានផង។

ក៖ អត់មានផង! ហើយអញ្ចឹងកាលដែលអ៊ុំស្រីនៅក្មេងចឹង តើអ្នកជិតខាងអី
គេហៅឈ្មោះអ៊ុំស្រី ថាម៉េចដែរ?

ខ៖ គេហៅថា មីង អង។

ក៖ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ខ្ញុំមានអាយុចិតសិបបួនឆ្នាំហើយ។

ក៖ អូ! អ្នកមីងអាយុចិតសិបបួនឆ្នាំហើយ។ ហើយអញ្ចឹង
តើអ្នកមីងមាននៅចាំថ្ងៃខែឆ្នាំកំណើតទេ អ្នកមីង?

ខ៖ ខ្ញុំមិនសូវចាំទេ។

ក៖ អ្នកមីងមិនសូវចាំទេ! អ្នកមីងអាយុចិតសិបបួនឆ្នាំ
អញ្ចឹងអ្នកមីងប្រហែលជាកើតក្នុងឆ្នាំមួយពាន់ប្រាំបួនរយសែសិបបួន។ ហើយអញ្ចឹង
អ្នកមីងកើតក្នុងឆ្នាំខ្មែរយើងដូចជា ជូត ឆ្លូត ខាល ថោះ តើអ្នកមីងបានកើតឆ្នាំណាដែរ
អ្នកមីង?

ខ៖ ខ្ញុំកើតឆ្នាំរកា។

ក៖ អូ! អ្នកមីងកើតឆ្នាំរកា។ ហើយអញ្ចឹង តើអ្នកមីងបានកើតនៅកន្លែងណាដែរ អ្នកមីង?

ខ៖ ខ្ញុំបានកើតនៅនឹងតែម្តង។

ក៖ ហើយអញ្ចឹង តើអ្នកមីងអាចជួយប្រាប់ឈ្មោះ ភូមិ ឃុំ ស្រុក បានទេអ្នកមីង?

ខ៖ ភូមិផ្អត់ដំរីខាងត្បូង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ ខ្ញុំមានបងប្អូនចំនួនប្រាំនាក់។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីមានបងប្អូនប្រុសប៉ុន្មាននាក់ ហើយស្រីប៉ុន្មាននាក់ដែរ អ៊ុំស្រី?

ខ៖ ខ្ញុំមានបងប្អូនប្រុសពីរនាក់ ហើយស្រីបីនាក់។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីមាននៅចាំឈ្មោះរបស់បងប្អូនទាំងប្រាំនាក់របស់អ៊ុំស្រីទេ?

ខ៖ នៅចាំតើ។

ក៖ ហើយអញ្ចឹង តើពួកគាត់មានឈ្មោះអ្វីខ្លះដែរ អ៊ុំស្រី?

ខ៖ ទីមួយឈ្មោះអឿន ហើយទីពីរឈ្មោះយឿន ហើយទីបីឈ្មោះច្រឹង
ហើយទីបួនឈ្មោះគៀង ហើយទីប្រាំឈ្មោះអេង ហើយទីប្រាំមួយខ្ញុំឈ្មោះ អង។

ក៖ អូ! អញ្ចឹងបងប្អូនរបស់អ៊ុំស្រីប្រាំមួយនាក់ហើយ។ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
តើបងប្អូនរបស់អ៊ុំស្រីទាំងប្រាំមួយនាក់នឹង ពួកគាត់រស់នៅកន្លែងណាដែរ អ៊ុំស្រី?

ខ៖ នៅភូមិសមខ្មែរ ហើយនៅជាប់គ្នានឹង ហើយនឹងឆ្លងផ្លូវនៅត្រង់នឹង
ហើយនឹងនៅជិតនឹង។

ក៖ ហើយអញ្ចឹង បងប្អូនរបស់អ៊ុំស្រីអត់មានទៅនៅខេត្តផ្សេងអីទេ អ៊ុំស្រី?

ខ៖ អត់មានទេ។

ក៖ ហើយអញ្ចឹង កាលនៅក្មេងៗអ៊ុំស្រីហើយនឹងបងប្អូនរបស់អ៊ុំស្រីចូលចិត្តធ្វើអ្វីខ្លះដែរ
អ៊ុំស្រី?

ខ៖ អត់មានធ្វើអីទេ ធ្វើតែស្រែមួយមុខទេ ធ្វើតែស្រែមែនមួយកូនចៅខ្ញុំហើយនឹងបងប្អូនខ្ញុំ
ដល់មកឥលូវកូនៗអីគេទៅឆ្ងាយខ្លះទៅ តែបើកូនចៅខ្ញុំគ្មានទៅណាទេ
នឹងកូនបងប្អូនទៅថៃទៅអីនោះ ចំណែកកូនចៅរបស់ខ្ញុំនៅធ្វើតែស្រែ។

ក៖ បងប្អូនអីនៅធ្វើតែស្រែ។

ខ៖ នៅធ្វើស្រែទាំងអស់គ្មានទៅណាទេ។

ក៖ ហើយអញ្ចឹង អ្នកមីងហើយនឹងបងប្អូនរបស់អ្នកមីងមានលេងប្រលែងគ្នាទេ អ្នកមីង?

ខ៖ ភ្លេចអស់ហើយ។

ក៖ ភ្លេចអស់ហើយ! ប៉ុន្តែមានមែនទេ មិនអត់ទេ?

ខ៖ មានមិនអត់ទេ គ្រាន់តែភ្លេចអស់។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះបងប្អូនរបស់អ្នកមីងប្រកបមុខរបរតែធ្វើស្រែទេ អ្នកមីង?

ខ៖ ចាំ! នៅតែធ្វើស្រែមួយមុខនឹង។

ក៖ ហើយអញ្ចឹង តើម្ដាយរបស់អ៊ុំស្រី តើគាត់មានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខ៖ ម្ដាយរបស់ខ្ញុំគាត់ឈ្មោះ យាយអ៊ឹម។

ក៖ យាយអ៊ឹម! ហើយអញ្ចឹង សព្វថ្ងៃនេះម្ដាយរបស់អ៊ុំស្រីគាត់នៅមានជីវិតរស់នៅ ឬមួយគាត់ស្លាប់បាត់ហើយ អ៊ុំស្រី?

ខ៖ ម្ដាយរបស់ខ្ញុំគាត់ស្លាប់បាត់ហើយ។

ក៖ ហើយអញ្ចឹងសំរាប់ម្ដាយរបស់អ៊ុំស្រីគាត់បានកើតនៅពេលណា អ៊ុំស្រីមាននៅចាំទេ?

ខ៖ ខ្ញុំអត់ចាំផង មិនដឹងជាគាត់កើតនៅពេលណាទេ។

ក៖ ហើយអញ្ចឹង តើម្ដាយរបស់អ៊ុំស្រីគាត់កើតឆ្នាំខ្មែរឆ្នាំអ្វី អ៊ុំស្រីមាននៅចាំទេ?

ខ៖ ខ្ញុំភ្លេចឆ្នាំដែរហើយ បងប្អូនខ្ញុំគាត់ចាំតែគ្រាន់តែគាត់អត់នៅ។

ក៖ ហើយអញ្ចឹង តើម្ដាយរបស់អ៊ុំស្រីគាត់បានកើតនៅកន្លែងណាដែរ អ៊ុំស្រី?

ខ៖ ម្ដាយរបស់ខ្ញុំគាត់បានកើតនៅភូមិក្រពើសា ក្បាលអូរនឹង។

ក៖ អញ្ចឹងភូមិក្រពើសា ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយអញ្ចឹង តើម្ដាយរបស់អ៊ុំស្រីគាត់បានស្លាប់ប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខ៖ អូ! យូរហើយតាំងពីមកពីកៀរ។

ក៖ តាំងពីឆ្នាំចិតប្រាំបួនមកម្លេះ។

ខ៖ តាំងពីមកពីកៀរមកគាត់ឈឺស្លាប់តែម្ដង។

ក៖ ហើយអញ្ចឹងកាលដែលម្ដាយរបស់អ៊ុំស្រីស្លាប់នឹង តើអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខ៖ ខ្ញុំក៏មិនដឹងថាអាយុប៉ុន្មានឆ្នាំដែរ ភ្លេចអស់ហើយ។

ក៖ យូរដែលហើយអ៊ុំស្រី!

ខ៖ ចាំ! យូរហើយខ្ញុំមិនសូវចាំផងភ្លេចមុខភ្លេចក្រោយ។

កៈ ហើយអញ្ចឹង កាលម្ដាយរបស់អ៊ុំស្រីគាត់នៅរស់ តើគាត់ប្រកបមុខរបរអ្វីដែរ អ៊ុំស្រី?

ខៈ គ្មានធ្វើអីទេ គាត់ធ្វើស្រែចឹងដែរ ធ្វើទល់កូនទល់ចៅដល់ឥលូវនឹង
មិនដែលធ្វើអីនឹងគេទេ។

កៈ ហើយអញ្ចឹង កាលម្ដាយរបស់អ៊ុំស្រីគាត់នៅរស់
តើគាត់មានចរិតលក្ខណៈយ៉ាងដូចម្ដេចដែរ អ៊ុំស្រី?

ខៈ ម្ដាយរបស់ខ្ញុំពីដើមគាត់រកអោយកូនហូបខ្វះខាតពិបាកចិត្តពេកទៅគាត់ហូបស្រា។

កៈ អូ! អញ្ចឹងគាត់ហូបទៅខូចសុខភាព។

ខៈ ចាំ!

កៈ ហើយអញ្ចឹង តើគាត់សុភាពរាបសា ឬក៏កាច អ៊ុំស្រី?

ខៈ ម្ដាយរបស់ខ្ញុំគាត់អត់កាចទេ គាត់ស្លូតណាស់ មិនផឹកស្រាកាចទេ គាត់ផឹកស្រាស្លូត
ដឹងតែពីសប្បាយ បើថាផឹកវិញអ្នកណាក៏កូន អ្នកណាក៏កូនអត់ចេះឈ្លោះ
ប៉ុន្តែគ្រាន់តែពេលមកផ្ទះប្ដីរបស់គាត់ខឹងទៅ
ឪពុករបស់ខ្ញុំក៏គាត់ហូបដែរប៉ុន្តែមិនដល់ថ្នាក់ឈ្លោះគ្នាវាយគ្នាទៅវិញទៅមកទេ អត់ទេ
គ្រាន់តែថាពេលគាត់ដើរអញ្ចឹងទៅខកបាយខកទឹកចឹងទៅពេលមកឪពុករបស់គាត់មាត់អី
ចឹងទៅ ឡូឡាទៅឆ្លងឆ្លើយគ្នាទៅវិញទៅមកទៅ
ហើយកូនចៅខ្លាចចេះតែឃាត់ចេះតែអង្វរទៅ។

កៈ ខ្ញុំចឹងដែរនឹងពេលឪពុករបស់ខ្ញុំគាត់ហូបស្រាពេលគាត់មកទៅ
គាត់ឡូឡាហើយអញ្ចឹងទៅម្ដាយរបស់ខ្ញុំគាត់អត់ហូប
ហើយគាត់ឡូឡាតបទៅវិញទៅចេះតែឈ្លោះគ្នា
ហើយអញ្ចឹងកូនចៅអត់សូវមានសុភមង្គលដែរ។ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំស្រី
តើគាត់មានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខៈ ឪពុករបស់ខ្ញុំគាត់មានឈ្មោះ យ៉ន។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើគាត់បានស្លាប់ហើយ
ឬមួយគាត់នៅមានជីវិតរស់នៅទេ?

ខៈ សំរាប់សព្វថ្ងៃនេះឪពុករបស់ខ្ញុំគាត់បានស្លាប់ហើយ គាត់ស្លាប់បានបីឆ្នាំហើយ។

កៈ អូ! គាត់ស្លាប់បានបីឆ្នាំហើយ។ ហើយអញ្ចឹង
តើឪពុករបស់អ៊ុំស្រីគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ៊ុំស្រី?

ខ៖ ឪពុករបស់ខ្ញុំគាត់ស្លាប់ដោយសារជម្ងឺតែម្ដង។

ក៖ អូ! គាត់ឈឺ!

ខ៖ ចា៎! គាត់ឈឺចាស់តែម្ដង គាត់អាយុកៅសិបប្រាំឆ្នាំហើយ។

ក៖ អូ! អញ្ចឹងគាត់ស្លាប់នៅអាយុកៅសិបប្រាំឆ្នាំ។ ហើយអញ្ចឹងគាត់ឈឺជំងឺជរាមែនទេ អ៊ុំស្រី?

ខ៖ គាត់ឈឺជម្ងឺជរាគាស់មិនឡើង។

ក៖ ហើយអញ្ចឹងពេលដែលគាត់ស្លាប់នឹង តើអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខ៖ ពេលដែលឪពុកខ្ញុំស្លាប់ខ្ញុំមានអាយុចិតសិបបីឆ្នាំ។

ក៖ អូ! អ៊ុំស្រីមានអាយុចិតសិបបីឆ្នាំឪពុករបស់អ៊ុំស្រីគាត់បានស្លាប់។ ហើយអញ្ចឹង តើគាត់បានស្លាប់នៅភូមិយើងនឹង ឬមួយគាត់បានស្លាប់នៅកន្លែងណាដែរ អ៊ុំស្រី?

ខ៖ គាត់ស្លាប់នៅផ្ទះបងខ្ញុំនៅនឹង។

ក៖ នៅភូមិក្រពើសានឹងមែនទេ?

ខ៖ នៅតាមផ្លូវនឹងទេ។

ក៖ អូ! នៅតាមផ្លូវយើងនឹងទេ អញ្ចឹងមានន័យថានៅភូមិផ្អត់ដំរីខាងត្បូង។ ហើយអញ្ចឹងកាលដែលឪពុករបស់អ៊ុំស្រីគាត់នៅរស់ តើគាត់រកស៊ីអ្វីដែរ អ៊ុំស្រី?

ខ៖ ឪពុករបស់ខ្ញុំកាលគាត់នៅរស់គាត់ធ្វើស្រែដែរ អត់មានធ្វើអីទេម៉ែឪរបស់មួយពូជនឹងគ្មានចំការកៅស៊ូ គ្មានចំការម្រេចអីនឹងគេទេ គិតនៅតែធ្វើស្រែបានស៊ីមិនបានស៊ីក៏នៅតែនឹងស្រែនឹង។

ក៖ ហើយអញ្ចឹងសំរាប់ឪពុករបស់អ៊ុំស្រី តើគាត់ជាមនុស្សមានចរិតលក្ខណៈយ៉ាងដូចម្ដេចដែរ អ៊ុំស្រី?

ខ៖ ឪពុករបស់ខ្ញុំគាត់ស្លូតណាស់ គាត់មិនសូវនិយាយច្រើន ហើយពេលគាត់អាយុច្រើនទៅគាត់លែងហូបស្រានឹងទៅគាត់ចូលទៅកាន់សីលរហូតដល់គាត់ស្លាប់នឹងតែម្ដង។

ក៖ អូ! គាត់កាន់សីលរហូតដល់គាត់ស្លាប់។

ខ៖ គាត់កាន់សីលរហូត ស្លូតមហាស្លូត។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីធ្លាប់មានអនុស្សាវរីយ៍ល្អៗជាមួយឪពុកម្តាយទេអ៊ុំស្រី ពីក្មេងៗមក?

ខ៖ ខ្ញុំមិនដែលជេរគាត់ ក្រែងតែបងប្អូនខ្ញុំមិនដឹងទេ
តែចំណែកខ្ញុំមួយខ្ញុំអត់ទេរឿងម៉ែឪនោះ ខ្ញុំមិនដែលឈ្លោះជាមួយគាត់
មិនមាត់តូចមាត់ធំជាមួយគាត់ ខ្លាចគាត់សឹងងាប់ហើយនឹង។

ក៖
ហើយអញ្ចឹងសំរាប់ឪពុកម្តាយរបស់អ៊ុំស្រីគាត់ធ្លាប់បានប្រាប់អ៊ុំស្រីអំពីជីវិតរបស់គាត់កាលគាត់នៅក្មេងៗដល់អ៊ុំស្រីទេ?

ខ៖ ឪពុកម្តាយរបស់ខ្ញុំគាត់មិនសូវជាអ្នកប្រាប់ផង។

ក៖ អូ! គាត់មិនសូវមាត់មិនសូវកទេ។

ខ៖ ចាំ! គាត់មិនសូវមាត់មិនសូវកទេ
ប្រវត្តិម៉ែឪរបស់ខ្ញុំសុទ្ធតែប្រវត្តិដូចត់អត់មានប្រវត្តិស្រួលនឹងគេទេ
មិនដែលធ្វើអោយអ្នកជិតខាងណាទាស់ចិត្តទេ គេធ្វើម៉េចក៏ដោយក៏នៅតែរៀងៗទៅ
នៅតែខាំមាត់សង្កត់ចិត្តនឹងទៅ មិនប៉ះពាល់គេទេស៊ូអោយគេប៉ះពាល់ខ្ញុំវិញ
គេធ្វើម៉េចស្រេចតែគេធ្វើទៅ យើងគ្រាន់តែមើលនឹង។

ក៖ ហើយអញ្ចឹងសំរាប់អ៊ុំស្រីមាននៅចាំឈ្មោះជីដូនជីតាខាងម្តាយរបស់អ៊ុំស្រីទេ?

ខ៖ ជីដូនជីតាខាងម្តាយរបស់ខ្ញុំគាត់ឈ្មោះ យាយអិត តាឡុង។

ក៖ ហើយអញ្ចឹងជីដូនជីតាខាងម្តាយរបស់អ៊ុំស្រីគាត់កើតពេលណា អ៊ុំស្រីដឹងទេ?

ខ៖ ខ្ញុំមិនសូវដឹងទេ ម៉ែឪគាត់នឹងណា ខ្ញុំវាមិនទាន់ដែរ។

ក៖ ហើយអញ្ចឹងមានន័យថាពេលដែលអ៊ុំស្រីកើតមកពួកគាត់បានស្លាប់អត់ហើយ។

ខ៖ ពេលដែលខ្ញុំកើតមកពួកគាត់បានស្លាប់អស់ហើយ។

ក៖ អូ! អញ្ចឹងបានអ៊ុំស្រីអត់ដឹង។

ខ៖ អត់ទានទេ យាយទូតនឹងនោះ។

ក៖ ហើយអញ្ចឹងអ៊ុំស្រីធ្លាប់ដឹងទេថា ពួកគាត់បានស្លាប់នៅកន្លែងណាដែរទេ អ៊ុំស្រី?

ខ៖ ខ្ញុំមិនដឹងដែរ។

ក៖ ព្រោះអីអ៊ុំស្រីកើតអត់ទាន់ផង។

ខ៖ ខ្ញុំកើតអត់ទាន់ផង ហើយម៉ែឪរបស់ខ្ញុំគាត់អត់បានប្រាប់
គាត់មិនបាននិយាយប្រាប់ផង។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ៊ុំស្រីទេ?

ខ៖ ជីដូនជីតាខាងឪពុករបស់ខ្ញុំគាត់ឈ្មោះយាយ ម៉េច ហើយតាខ្ញុំក៏អត់ស្គាល់ដែរ។

ក៖ អូ! អ៊ុំស្រីគាត់តែយាយអត់ស្គាល់តាទេ។

ខ៖ ខ្ញុំគាត់យាយម៉េចនឹងណា ហើយបើម៉ែឪរបស់ឪរបស់ខ្ញុំនឹងឈ្មោះតាសែម យាយសួង។

ក៖ អូ! ឈ្មោះតាសែម យាយសួង។ ហើយអញ្ចឹងសំរាប់ម៉ែឪខាងឪពុកនឹង
តើអ៊ុំស្រីកើតមកទាន់ពួកគាត់ទេ អ៊ុំស្រី?

ខ៖ ខ្ញុំកើតមកទាន់ពួកគាត់។

ក៖ អូ! អញ្ចឹងអ៊ុំស្រីបាននៅជាមួយនឹងពួកគាត់ដែរ មែនទេ អ៊ុំស្រី?

ខ៖ ចាំ! ខ្ញុំបានដូចថាបាយទឹកអីពេលដែលខ្ញុំមកលេងមកអីនឹងណា។

ក៖ ហើយអញ្ចឹង ជីដូនជីតាខាងឪពុករបស់អ៊ុំស្រីគាត់បានកើតនៅពេលណាអ៊ុំស្រីដឹងទេ?

ខ៖ ខ្ញុំអត់ចាំទេ។

ក៖ ហើយអញ្ចឹង តើពួកគាត់បានកើតនៅកន្លែងណា អ៊ុំស្រីដឹងទេ?

ខ៖ ពួកគាត់កើតនឹងប្រហែលជានៅភូមិក្រពើសានឹង។

ក៖ អូ! ពួកគាត់កើតនៅភូមិក្រពើសារនឹងហ៎! ហើយអញ្ចឹង
តើពួកគាត់បានស្លាប់នៅកន្លែងណាដែរ អ៊ុំស្រី?

ខ៖ ពួកគាត់បានស្លាប់នៅភូមិផ្អត់ដំរីយើងនឹង។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីធ្លាប់មានអនុស្សាវរីយ៍ជាមួយជីដូនជីតាទេ អ៊ុំស្រី?

ខ៖ គ្មានទេ។

កៈ តែអ៊ុំស្រីធ្លាប់បានបំរើបាយទឹកអោយពួកគាត់ដែរ មែនទេអ៊ុំស្រី?

ខៈ បាយទឹកខ្ញុំបំរើពួកគាត់ តែពួកខ្ញុំវានៅឆ្ងាយបំរើគាត់មិនជិតដល់ទេ។

កៈ ហើយអញ្ចឹង កាលនឹងអ៊ុំស្រីរស់នៅកន្លែងណាដែរ អ៊ុំស្រី?

ខៈ កាលនឹងខ្ញុំរស់នៅមេមត់ឯណោះ។

កៈ អូ! អ៊ុំស្រីនៅមេមត់។

ខៈ ហ្នឹងហើយ! ខ្ញុំទៅរកស៊ីនៅខាងមេមត់ មកពីកៀរវិញនោះ។

កៈ អូ! អញ្ចឹងមានន័យថាពេលត្រឡប់មកពីឆ្នាំចិតសិបប្រាំមក
អ៊ុំស្រីបានឡើងទៅរកស៊ីនៅមេមត់។

ខៈ ចាំ! ឡើងទៅរកស៊ីនៅមេមត់។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីទៅរកស៊ីអ្វីដែរនៅទៅនោះ?

ខៈ ខ្ញុំរកស៊ីចាក់ជ័រ។

កៈ អូ! រកស៊ីចាក់ជ័រកៅស៊ូ។ អញ្ចឹងពេលដែលអ៊ុំស្រីមកលេងម្តងៗទៅ អ៊ុំស្រីបំរើបាយទឹក
ហើយជូនលុយជូនកាក់អោយគាត់ចឹងទៅ។

ខៈ ចាំ! ជូនទៅទិញខោអាវរងាជូនគាត់ទៅ។

កៈ
ហើយអញ្ចឹងសំរាប់ក្រុមគ្រួសាររបស់អ៊ុំស្រីបានរស់នៅក្នុងខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំ
ហើយ អ៊ុំស្រី?

ខៈ ខ្ញុំរស់នៅនឹងរាប់ឆ្នាំមិនឈ្នះហើយទេ។

កៈ តាំងពីកើតមកតែម្តង!

ខៈ ហ្នឹងហើយ! តាំងពីកើតមកតែម្តង។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីមានសាច់ញាតិដែលរស់នៅក្រៅប្រទេសខ្មែរយើងទេ អ៊ុំស្រី?

ខៈ គ្មានតែម្តង។

កៈ គ្មានសោះតែម្តង!

ខ៖ មានកូននេះមួយទៅថៃ។

ក៖ កូនរបស់អ៊ុំស្រីផ្ទាល់ ឬមួយកូនរបស់អ្នកណាគេដែរ អ៊ុំស្រី?

ខ៖ កូនរបស់បងប្អូន។

ក៖ អញ្ចឹងត្រូវជាក្មួយរបស់អ៊ុំស្រី។

ខ៖ ហ្នឹងហើយ! ត្រូវជាក្មួយ។

ក៖ អញ្ចឹងមានក្មួយនៅប្រទេសថៃ។ហើយអញ្ចឹង តើគាត់ទៅនៅនឹង ឬមួយគាត់ទៅធ្វើការទេ អ៊ុំស្រី?

ខ៖ គាត់ទៅធ្វើការ។

ក៖ ហើយអញ្ចឹង តើស្វាមីរបស់អ៊ុំស្រីគាត់មានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខ៖ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះ ទិត សួង។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីបានរៀបការជាមួយគាត់នៅពេលណាដែរ អ៊ុំស្រី?

ខ៖ ខ្ញុំភ្លេចដែរហើយ។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីបានរៀបការក្រោយឆ្នាំចិតសិបប្រាំបួន ឬក៏មុនឆ្នាំចិតសិបប្រាំបួន អ៊ុំស្រី?

ខ៖ ខ្ញុំរៀបការមុនឆ្នាំចិតសិបប្រាំបួនទេ។

ក៖ អូ! អ៊ុំស្រីបានរៀបការមុនឆ្នាំចិតសិបប្រាំបួន។ ហើយអញ្ចឹង តើអ៊ុំស្រីបានរៀបការក្នុងសម័យពលពតតែម្តង ឬមួយយ៉ាងម៉េចដែរ អ៊ុំស្រី?

ខ៖ អត់ទេ ខ្ញុំបានរៀបការមុនសម័យពលពតទៀត។

ក៖ អូ! អ៊ុំស្រីបានរៀបការមុនសម័យពលពតទៀត។ ហើយអញ្ចឹងមកដល់សព្វថ្ងៃនេះ តើអ៊ុំស្រីបានរៀបការជាមួយប្តីរបស់អ៊ុំស្រីបានប៉ុន្មានឆ្នាំហើយអ៊ុំស្រី?

ខ៖ រៀបការនឹងយូរហើយ ខ្ញុំភ្លេចហើយ។

ក៖ ហើយអញ្ចឹង ពេលដែលអ៊ុំស្រីរៀបការនឹង តើអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រីដឹងទេ?

ខ៖ ពេលរៀបការនឹងខ្ញុំមានអាយុដប់ប្រាំឆ្នាំ។

ក៖ អូ! អ៊ុំស្រីបានរៀបការនៅក្មេងដែរ។ហើយអញ្ចឹង
តើអ៊ុំស្រីបានរៀបការនៅកន្លែងណាដែរ អ៊ុំស្រី?

ខ៖ ខ្ញុំបានរៀបការនៅគីឡូសែសិបប្រាំបី(គីឡូសែសិបប្រាំបី មានន័យថា
ឈ្មោះភូមិនៅក្នុងចំការកៅស៊ូ)។

ក៖ ហើយអញ្ចឹង តើគីឡូសែសិបប្រាំនឹង នៅឯណាដែរ អ៊ុំស្រី?

ខ៖ នៅខាងជើងក្រុងសួង។

ក៖ នៅខាងជើងក្រុងសួង!
ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍មួយនឹងត្រូវបានរៀបចំឡើងដោយឪពុកម្តាយ
ឬមួយអ៊ុំស្រីរៀបចំឡើងដោយខ្លួនឯង?

ខ៖ ឪពុកម្តាយរបស់ខ្ញុំគាត់អ្នករៀបចំអោយ។

ក៖ អូ! ឪពុកម្តាយរបស់អ៊ុំស្រីជាអ្នករៀបចំអោយ។

ខ៖ ចាំ! ឪពុកម្តាយរបស់ខ្ញុំគាត់ជាអ្នករៀបចំអោយ។

ក៖ ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍នឹងមានថ្លៃជំនួនទេ អ៊ុំស្រី?

ខ៖ មានតើជំនួន។

ក៖ ហើយអញ្ចឹង តើថ្លៃជំនួនកាលនឹងថ្លៃប៉ុន្មានដែរ អ៊ុំស្រី?

ខ៖ ខ្ញុំមិនដឹងប៉ុន្មានទេ នៅលើម៉ែឪរបស់ខ្ញុំទេ។

ក៖ អូ! អញ្ចឹងអ៊ុំស្រីអត់ដឹងទេ។

ខ៖ ខ្ញុំអត់ដឹងទេ ដឹងតែការតែម្តង។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីហើយនឹងអ៊ុំប្រុសធ្លាប់បានជួបគ្នាពីមុនដែរ
ឬក៏ដល់ថ្ងៃរៀបការទើបបានជួបគ្នា អ៊ុំស្រី?

ខ៖ ជួបគ្នាមុន ខ្ញុំខ្វះខាតចឹង ខ្ញុំទៅស៊ីឈ្នួលនៅគីឡូនឹង ដល់ទៅរកស៊ីបានតែមួយឆ្នាំ
ដល់គេឃើញខ្ញុំទៅគេស្តីដណ្តឹងទៅណា។

កៈ អូ! អញ្ចឹងគាត់បានឃើញអ៊ុំស្រីហើយ គាត់បានអោយឪពុកម្ដាយរបស់គាត់មកចូលស្ដីដណ្ដឹងយកធ្វើជាភរិយា។ ល្អតើអ៊ុំស្រី យើងធ្វើតាមប្រពៃណី យើងអត់បានខុសឆ្គងទេ។ ហើយ អញ្ចឹង សំរាប់អាពាហ៍ពិពាហ៍អ៊ុំស្រីជាមួយអ៊ុំប្រុសនឹងមានកូនចំនួនប៉ុន្មាននាក់ដែរ អ៊ុំស្រី?

ខៈ ខ្ញុំមានកូនចំនួនប្រាំពីរនាក់។

កៈ អូ! កូនប្រាំពីរនាក់ ច្រើនដែរតើអ៊ុំស្រី! ហើយអញ្ចឹង តើអ៊ុំស្រីមានកូនប្រុសប៉ុន្មាននាក់ ហើយស្រីប៉ុន្មាននាក់ដែរ អ៊ុំស្រី?

ខៈ ខ្ញុំមានកូនប្រុសម្នាក់ ហើយស្រីប្រាំមួយនាក់។

កៈ អូ! បានកូនស្រីច្រើនផងអ៊ុំស្រី! ហើយអញ្ចឹង តើអ៊ុំស្រីអាចជួយរៀបរាប់ឈ្មោះកូនទាំងប្រាំពីរនាក់របស់អ៊ុំស្រីបានទេ?

ខៈ ទីមួយឈ្មោះអុល កូនស្រី ហើយទីពីរឈ្មោះអាត កូនស្រី ហើយទីបីអុន កូនស្រី ហើយបួនឈ្មោះទូច កូនស្រី ហើយទីប្រាំឈ្មោះភា កូនស្រី ហើយទីប្រាំមួយឈ្មោះផាត់ កូនស្រី ហើយទីប្រាំពីរឈ្មោះធី កូនប្រុស។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើបងធីគាត់មានអាយុប៉ុន្មានឆ្នាំហើយអ៊ុំស្រី?

ខៈ គាត់ឆ្នាំកុរ ប្រហែលជាសាមជាងហើយ។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីធ្លាប់មានអនុស្សាវរីយ៍អ្វីល្អៗជាមួយកូនទេ អ៊ុំស្រី?

ខៈ ខ្ញុំចិញ្ចឹមកូនធំជ្រោង ខ្ញុំមិនដែលជេរប្រចោលកូនមួយណាអោយបានផ្អើលគេផ្អើលឯងទេ ខ្ញុំមិនដែលទេ មានតែកូនរំលោភលើខ្ញុំវិញទេ មានតែកូនសំឡុតខ្ញុំវិញទេ មិនដែលរំលោភលើកូនណាទេ មិនមែនស្រឡាញ់ស្អប់មួយទេ ស្រឡាញ់ស្មើគ្នាទាំងអស់ ប៉ុន្តែខ្ញុំសំរាប់ខែបុណ្យខែទានកូនជូនមិនជូន ខ្ញុំមិនដែលថាទេ ស្រេចតែលើចិត្តកូនទេ។

កៈ សូមអោយតែកូនមានសេចក្ដីសុខ!

ខៈ បើកូនអោយស៊ីខ្ញុំស៊ី ហើយបើកូនមិនអោយស៊ីទេ អើយផ្ទះយើងមានហូបទៅ។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីចេះអាននិងសរសេរអក្សរខ្មែរទេ អ៊ុំស្រី?

ខៈ មិនចេះទេ មិនចេះសោះតែម្ដង គោងតែកន្ទុយក្របី កន្ទុយគោទេ។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីចេះភាសាផ្សេងក្រៅពីភាសាខ្មែរទេ អ៊ុំស្រី?

ខៈ ស្អីក៏មិនចេះដែរ។

កៈ ហើយអញ្ចឹង តើអ៊ុំស្រីមិនដែលបានចូលរៀននៅក្នុងសាលាទេ អ៊ុំស្រី?

ខៈ មិនដែលទេ មើលតែក្របីមែន។

កៈ ហើយអញ្ចឹង សំរាប់អ៊ុំស្រីពីក្មេងមកមានមិត្តភក្តិជិតស្និតដែលធំធាត់មកជាមួយគ្នាទេ អ៊ុំស្រី?

ខៈ មិត្តភក្តិនឹងគ្មានទេ មានតែអ្នកស្រុកបងប្អូននឹងរាប់អានគ្នាជិតស្និតនឹងរាល់ថ្ងៃ មានតែបងប្អូន មិត្តភក្តិគ្មាននឹងគេទេ។

កៈ បងប្អូនបង្កើតមែនទេ អ៊ុំស្រី?

ខៈ បងប្អូនជីដូនមួយ នឹងបងប្អូនញាតិជិតខាងនឹង។

កៈ ហើយអញ្ចឹង អ្នកជិតខាងដែលអ៊ុំស្រីរាប់អានជាមួយគាត់នឹង តើគាត់មានឈ្មោះអ្វីដែរ អ៊ុំស្រី?

ខៈ គាត់ឈ្មោះយាយអិត។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំស្រី?

ខៈ គាត់មានអាយុចិតសិបបួនឆ្នាំហើយ។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះគាត់រស់នៅកន្លែងណាដែរ អ៊ុំស្រី?

ខៈ គាត់រស់នៅនឹង រស់នៅខាងកើតផ្ទះខ្ញុំនឹង។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះគាត់ធ្វើការងារអ្វីដែរ អ៊ុំស្រី?

ខៈ គាត់គ្មានធ្វើការអីទេ មើលតែចៅព្រោះអីម៉ែឪវាទៅធ្វើការនៅប្រទេសថៃអស់ហើយ។

កៈ ហើយអញ្ចឹង កាលនៅពីក្មេង តើអ៊ុំស្រីហើយនឹងគាត់ចូលចិត្តធ្វើអ្វីខ្លះដែរ អ៊ុំស្រី?

ខៈ គ្មានធ្វើអីទេ ដកតែព្រៃ ធ្វើតែកន្ទេល។

កៈ អូ! អញ្ចឹង តើអ៊ុំស្រីចេះត្បាញកន្ទេលមែនទេ?

ខ៖ ចាំ!

ក៖ ត្បាញកន្ទេលយកទៅលក់មែនទេ អ៊ុំស្រី?

ខ៖ មិនលក់ទេ ត្បាញដេកខ្លួនឯង ចូលចិត្តមានតែគ្រឿងចឹងទេ ធ្វើជាមួយគ្នាទៅ ងងុយដេកក៏ទៅ ហើយបើមិនងងុយទេចេះតែត្បាញសើចចឹងទៅ។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីមានធ្វើស្រែចំការទេ អ៊ុំស្រី?

ខ៖ អត់ទេ មានតែស្រែមួយមុខទេ។

ក៖ អូ! អញ្ចឹងអ៊ុំស្រីធ្វើស្រែ តែអត់មានចំការទេ។

ខ៖ ចាំ! អត់មានចំការទេ មានតែស្រែ។

ក៖ ហើយអញ្ចឹង ក្រៅពីធ្វើស្រែ តើអ៊ុំស្រីមានធ្វើអ្វីផ្សេងទៀត សំរាប់ចិញ្ចឹមជីវិតដែរទេ?

ខ៖ គ្មានសោះតែម្តង។

ក៖ ហើយអញ្ចឹង សំរាប់អ៊ុំស្រីតាំងពីក្មេងរហូតមកដល់ពេលនេះ តើអ៊ុំស្រីគិតថាជីវិតរបស់អ៊ុំស្រីមានការផ្លាស់ប្តូរទេ?

ខ៖ មានការផ្លាស់ប្តូរហើយ ខ្លួនធ្វើការមិនកើតកាន់តែចាស់ហើយ។

ក៖
តែសំរាប់ជីវិតអ៊ុំស្រីពីមុនពិបាកហើយចុះសំរាប់ឥលូវនៅតែពិបាកដែរឬមួយបានធូរស្រាលជាងមុនហើយ?

ខ៖ វាបានធូរជាងមុខបន្តិច ធូរនឹងគ្រាន់តែថាយើងមានទីច្រកស្រួលមានផ្ទះសំបែង ទើបបាននៅឆ្នាំមុនទេ តែនៅជំពាក់លុយគេទាំងស្រុង។

ក៖ តែម៉េចក៏យើងបានធូរក្នុងចិត្តរបស់យើងថា យើងមានផ្ទះដើម្បីច្រកភ្លៀងអីត្រឹមត្រូវអីចឹង។

ខ៖ ប៉ុន្តែរឿងធ្វើផ្ទះមួយៗរឿងអីមិនជំពាក់គេ។

ក៖ ហើយអញ្ចឹងសំរាប់ម្ហូប តើមានម្ហូបណាដែលអ៊ុំស្រីចូលចិត្តហូបជាងគេទេ អ៊ុំស្រី?

ខ៖ ខ្ញុំសព្វថ្ងៃនឹងវាគ្មានអីហូបទេ ប៉ុន្តែហូបតែត្រីងៀតដែលកូនចៅទិញមកជូននឹងណា កូនចៅគេទិញមកជូនហូបត្រីដែលគេទិញមកអោយនឹងទៅ ហើយបើគ្មានទេប្រហុកអំបិលនឹងទៅ។

ក៖ ហើយអញ្ចឹង សំរាប់កាលពីក្មេងៗអ៊ុំស្រីមានចូលចិត្តលេងល្បែងប្រជាប្រិយខ្មែរយើងដូចជា បោះឈូង បោះអង្គញ់ ទាញព្រ័ត្រអីទេ អ៊ុំស្រី?

ខ៖ លេងតើ។

ក៖ អញ្ចឹង អ៊ុំស្រីចូលចិត្តលេងដែរ?

ខ៖ ចូលចិត្តលេងតើ។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីចូលចិត្តលេងល្បែងអ្វីជាងគេដែរ អ៊ុំស្រី?

ខ៖ ឈូងខ្ញុំមិនសូវលេងនឹងគេទេ ហើយអង្គញ់ក៏ខ្ញុំមិនសូវលេងនឹងគេដែរ ទាញព្រ័ត្រក៏ខ្ញុំមិនសូវទាញដែរ ខ្ញុំចូលចិត្តតែចំរៀងច្រៀងរាំតែម្តង។

ក៖ អូ! អញ្ចឹងមានន័យថា អ៊ុំស្រីចូលចិត្តរាំវង់ រាំក្បាច់។

ខ៖ ចូលចិត្តតែរាំវង់ ទល់តែចំណាស់នឹងនៅតែចូលចិត្តអញ្ចឹង។

ក៖ ហើយអញ្ចឹង សំរាប់បទចម្រៀង តើមានបទចម្រៀងណាដែលអ៊ុំស្រីចូលចិត្តស្តាប់ហើយរៀនច្រៀងតាមអី តាំងពីក្មេងរហូតមកដល់ពេលនេះ មានទេ អ៊ុំស្រី?

ខ៖ ចម្រៀងនឹងពីជំនាន់ចាស់មកចាំខ្លះភ្លេចខ្លះហើយ។

ក៖ ហើយអញ្ចឹង តើនៅក្នុងក្រុមគ្រួសាររបស់អ៊ុំស្រីមាននរណាម្នាក់ដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរឬទេ អ៊ុំស្រី?

ខ៖ គ្មានទេ គ្មាននរណាចេះលេងទេកូនចៅនឹងនោះ។

ក៖ ហើយអញ្ចឹង ផ្ទះរបស់អ៊ុំស្រីផ្ទះនៅក្មេងៗមានលក្ខណៈដូចម្តេចដែរអ៊ុំស្រី ជាផ្ទះទាប ឬមួយផ្ទះខ្ពស់?

ខ៖ ផ្ទះតូចការត្រេកការត្រាក(ការត្រេកការត្រាក មានន័យថាចាស់ខ្លាំងណាស់) ភ្លៀងមកលេច ប្ដីខ្ញុំដែលស្លាប់ទៅនឹងភ្លៀងលេចទទឹក ក្របីនៅហាលភ្លៀង គ្មានស្អីនឹងគេទេខ្ញុំពិបាកណាស់។

ក៖ ហើយអញ្ចឹងផ្ទះដែលលំបាកនឹង តើផ្ទះនឹងឪពុកម្ដាយរបស់អ៊ុំស្រីជាអ្នកធ្វើ ឬមួយអ៊ុំស្រីធ្វើឡើងដោយខ្លួនឯង អ៊ុំស្រី?

ខ៖ នោះកូនចៅនឹងវារកស៊ីបានលុយតិចតួចទៅវាបំរុងទិញយកមកច្រកទៅណា កូនចៅទេវាអ្នកទិញនោះតម្លៃហាហុកសិបម៉ឺន។

ក៖ ហើយអញ្ចឹង ទិញផ្ទះគេស្រាប់តែម្ដង អ៊ុំស្រី?

ខ៖ ហ្នឹងហើយ! ទិញផ្ទះគេស្រាប់។

ក៖ ហើយអញ្ចឹង នៅពេលយកមកធ្វើនឹង តើគាត់ធ្វើដោយខ្លួនឯង ឬមួយគាត់បានជួលគេអោយធ្វើអោយដែរ អ៊ុំស្រី?

ខ៖ ជួលគេទាំងអស់ កូនសុទ្ធតែស្រីមាននរណាចេះធ្វើ។

ក៖ ហើយអញ្ចឹង តើអ៊ុំស្រីមានជំនាញដែលបន្តវេនពីក្រុមគ្រួសារទេ ដូចជាវេញវល្លិ៍ផ្ដៅ ឬជំនាញធ្វើស្ករត្នោត ឬក៏ត្បាញអីមានទេ អ៊ុំស្រី?

ខ៖ គ្មានទេ។

ក៖ ហើយអញ្ចឹង តើជីវិតរបស់អ៊ុំស្រីមានបានឆ្លងកាត់សម័យសង្គ្រាមទេ អ៊ុំស្រី?

ខ៖ ឆ្លងតើ។

ក៖ ហើយអញ្ចឹង តើជំនាន់ពលពតនឹងអ៊ុំស្រីត្រូវបានគេចាត់អោយទៅកន្លែងណា ហើយគេអោយអ៊ុំស្រីធ្វើអ្វីដែរ?

ខ៖ គេអោយទៅខាងស្រុកសណ្ដាន់ ឃុំពព្រាយថ្មី ទៅហួសពីខេត្តកំពង់ធំទៅហួសដល់ណាដល់ណី លេចវាលចូលព្រៃ ព្រៃខ្លាព្រៃដំរី។

ក៖ ហើយអញ្ចឹង ទៅនឹងគេអោយអ៊ុំស្រីធ្វើអ្វីដែរ អ៊ុំស្រី?

ខ៖ ទៅនឹងគេអោយច្រូតស្រូវ។

ក៖ អូ! គេអោយអ៊ុំស្រីច្រូតស្រូវ!

ខ៖ គេអោយច្រូត ហើយគេអោយទូលអុស គេអោយរកអុសអោយគេ។

ក៖ ហើយអញ្ជឹង នៅក្នុងសម័យពលពតនឹង តើអ៊ុំស្រីមានត្រូវបានគេធ្វើបាបធ្វើអីទេ អ៊ុំស្រី ដូចជាវាយដំអីទេ?

ខ៖ នៅទេមិនទាន់បានវាយដំទេ ដូចថាថ្ងៃនេះគេជប់លៀងហើយ គេយកត្បាលថ្មមកគេកិនម្សៅជប់លៀង ហើយល្ងាចនឹងគេយកទៅដាក់ក្នុងរណ្តៅវាយចោលហើយ។ តែទទួលនឹងគេរំដោះទៅ។

ក៖ អញ្ជឹងមានន័យថា អ៊ុំស្រីគេជិតយកទៅវាយចោលហើយនឹង។

ខ៖ គេជិតយកទៅវាយចោលហើយ ថ្ងៃនេះពេលល្ងាចគេយកទៅវាយចោលហើយតែបានគេរំដោះទាន់។

ក៖ អញ្ជឹងអ៊ុំស្រីសំណាងល្អណាស់ កម្រមានអ្នកមានសំណាងល្អអញ្ជឹងណាស់ដែលមានឪកាសនៅរស់។ ហើយអញ្ជឹង នៅពេលជំនាន់ពលពតនឹង តើអ៊ុំស្រីហើយនឹងអ៊ុំប្រុសបានបែកគ្នាដែរ ឬក៏យ៉ាងម៉េចដែរអ៊ុំស្រី នៅជុំគ្នាទេ?

ខ៖ អត់បែកទេនៅជុំគ្នា ប្តីខ្ញុំគាត់ចេះនិយាយវៀតណាម ហើយពេលខ្ញុំវិលត្រឡប់មកផ្ទះវិញសុំអង្ករ សុំស្រូវគេតាមផ្លូវនឹងណា ចេះតែសូម ហើយគេចេះតែផ្តល់អោយរហូតមកដល់ផ្ទះនឹង។

ក៖ ហើយអញ្ជឹង ពេលសម័យសង្គ្រាមនឹង តើអ៊ុំស្រីមានកូនហើយឬនៅទេ អ៊ុំស្រី?

ខ៖ សម័យសង្គ្រាមនឹងខ្ញុំមានកូនបីនាក់ហើយ។

ក៖ អូ! អ៊ុំស្រីមានកូនបីនាក់ហើយ! យកទៅទាំងអស់ជាមួយគ្នានឹងមែនទេ អ៊ុំស្រី?

ខ៖ ចាំ! អត់ទេកូនពីរទេ កូនពីរនាក់ទេទៅតាមសុទ្ធតែស្រី ប៉ុន្តែវាធំៗអស់ហើយបានវាចេះដើរខ្លួនឯងខ្លះ។

ក៖ ហើយអញ្ជឹងសំរាប់អ៊ុំស្រី តើអ៊ុំស្រីមានពេលដែលលំបាកជាងគេនៅក្នុងជីវិតទេ អ៊ុំស្រី?

ខ៖ លំបាកណាស់មួយគ្រួសាររបស់ខ្ញុំ លំបាកបានព្រឹកខ្វះល្ងាច ទៅខ្ចីចិនគេមិនអោយទៀត ទាល់តែមានគេអ្នកធានាព្រោះអីខ្ញុំកូនច្រើន គេខ្លាចយើងអត់បានសងគេ ទាល់តែមានគេធានា អោយគេអោយពីរបីគីឡូមក ដោះអាចមិដោះនោមគេដោះការគេ វេទនាណាស់គ្រួសារខ្ញុំ ប្រវត្តិជូរចត់នឹងមិនបាននិយាយណាស់។

ក៖ ហើយអញ្ចឹង អ៊ុំស្រីធ្លាប់មានបទពិសោធន៍ល្អៗនៅក្នុងជីវិតទេ ដូចជារៀបការកូន ឬបុណ្យទាន អីចឹងណាអ៊ុំស្រី?

ខ៖ ខ្ញុំអត់អីទេ ធ្លាប់ធ្វើបុណ្យស្មោះនឹងធ្វើបុណ្យហើយ រៀបការកូនទោះបីជាខ្ញុំជំពាក់គេប៉ុនណាក៏ខ្ញុំរូតរះរៀបការកូនទាល់តែបាន កូនខ្ញុំគ្មានអោយរត់តាមពីណាមួយទេ ក្បាលដល់កន្ទេលទាំងអស់។

ក៖ ល្អណាស់អ៊ុំស្រីបានកូនគាត់ស្ដាប់បង្គប់។

ខ៖ គ្មានរត់ទៅណាមកណាតាមគេតាមឯងគ្មានទេ គ្មានស្នេហាគ្មានណាទេ មានតែគេចូលស្ដី ដណ្ដឹងរៀបការតែម្ដង។

ក៖ ហើយអញ្ចឹង នៅពេលអ៊ុំស្រីនៅក្មេងៗ តើអ៊ុំស្រីធ្លាប់មានក្ដីសង្ឃឹមថាចង់ធ្វើអ្វីមួយនៅពេលអ៊ុំស្រីធំឡើងទេ?

ខ៖ មាន។

ក៖ ហើយអញ្ចឹង ពេលនៅក្មេងៗអ៊ុំស្រីប្រាថ្នាចង់ធ្វើអ្វីដែរ អ៊ុំស្រី?

ខ៖ ប្រាថ្នានឹងមិនចង់ធ្វើស្រែទេ ចង់អោយបានប្រាក់ខែស៊ីនឹងគេនឹង។

ក៖ ចង់មានការងារល្អធ្វើជាមួយគេចឹងទៅណា។

ខ៖ ចង់អោយចេះដឹងនឹងគេឡើងកុំអោយល្ងង់ពេក ដូចខ្ញុំនឹងល្ងង់ណាស់ ខ្ញុំមិនដឹងធ្វើអីនឹងគេទេ ចេះតែធ្វើស្រែមួយមុខទេ។

ក៖ ហើយអញ្ចឹង ជាចុងក្រោយបើសិនជាអ៊ុំស្រីចង់ផ្ដាំផ្ញើរសំរាប់កូនចៅជំនាន់ក្រោយ តើអ៊ុំស្រីនឹងផ្ដាំផ្ញើរប្រាប់ពួកគាត់អ្វីខ្លះដែរ អ៊ុំស្រី?

ខ៖ ផ្ដាំផ្ញើរកូនចៅសព្វថ្ងៃខ្ញុំថា បើអត់ពីខ្ញុំទៅ កុំអោយឈ្លោះប្រកែកនឹងអ្នកជិតខាង កុំរករឿងនឹងគេ ដូចថាដីធ្លីនឹងគេទុកអោយប៉ុនណាយើងនៅប៉ុននឹងទៅ កុំទាស់ទែងតែពីរឿងដី។ តែយើងធ្វើល្អបានល្អហើយ ហើយបើយើងធ្វើអាក្រក់ណាស់តែយើងខ្លាំងយើងនៅមិនបានសុខទេ។

ក៖ ហើយអញ្ចឹង បើសិនជាអ៊ុំស្រីចង់អោយកូនចៅរបស់អ៊ុំស្រីជៀសវាង តើអ៊ុំស្រីចង់អោយពួកគាត់ជៀសវាងពីអ្វីខ្លះដែរ អ៊ុំស្រី?

ខ៖ អោយជៀសវាងពីរឿងឈ្លោះប្រកែកគ្នា ទំនាស់ទាស់ទែងពីរឿងដីធ្លីចឹង។

កៈ ហើយអញ្ចឹងសំរាប់រឿងគ្រឿងញៀងអី តើអ៊ុំស្រីចង់អោយគាត់ជៀសវាងទេ?

ខៈ ចង់សឹងងាប់ហើយ ខ្ញុំមិនអោយមានទេ។

កៈ អរគុណាច្រើនហើយអ៊ុំស្រី
សំរាប់អ៊ុំស្រីចំណាយពេលវេលាសំរាប់អោយខ្ញុំសម្ភាសន៍អ៊ុំស្រី
ហើយអញ្ចឹងសំរាប់ចុងក្រោយខ្ញុំសូមជូនពរអ៊ុំស្រីអោយមានសុខភាពល្អ មានកំលាំងមាំមួន
មានប្រាជ្ញាវៀងវៃ មានសុភមង្គលនៅក្នុងក្រុមគ្រួសារ
ហើយក៏ជូនពរទៅកាន់កូនចៅទាំងអស់របស់អ៊ុំស្រី សូមអោយគាត់មានសុខភាពល្អ
មានប្រាជ្ញាវៀងវៃ ហើយថាគាត់នឹងជោគជ័យលើគ្រប់ឧបសគ្គដែលគាត់មានចឹងណា
ហើយថាជោគជ័យលើមុខរបររកស៊ីរបស់គាត់។ ហើយអញ្ចឹងអ៊ុំស្រីសំរាប់ខ្ញុំ
សំរាប់ការសម្ភាសន៍នឹងខ្ញុំនឹងដាក់ការសម្ភាសន៍នឹងទៅកាន់វេបសាយរបស់សាកលវិទ្យាល័
យដើម្បីទុកអោយកូនចៅរបស់អ៊ុំស្រីជំនាន់ក្រោយមើល។ ហើយអញ្ចឹង
តើអ៊ុំស្រីយល់ព្រមអោយខ្ញុំដាក់សំលេងហើយនឹងរូបថតរបស់អ៊ុំស្រីនៅលើវេបសាយរបស់
សាកលវិទ្យាល័យទេអ៊ុំស្រី?

ខៈ យល់ព្រម។

កៈ អញ្ចឹង អរគុណាច្រើនហើយអ៊ុំស្រី។